គណបក្ស សម រង្ស៊ី

SAM RAINSY PARTY

PARTI SAM RAINSY

សីលធម៌ សច្ចធម៌ យុត្តិធម៌

# សេចក្តីជូនដំណឹង

អគ្គលេខាធិការគណបក្ស សម រង្ស៊ី សូមជំរាបជូនដំណឹងដល់សមាជិក-សមាជិកាគណបក្សទាំងក្នុងប្រទេស ក្រៅប្រទេស និងជនរួមជាតិទាំងអស់ មេត្តាជ្រាបថា នៅថ្ងៃពុធ ទី៣០ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨ ព្រឹក គណបក្ស សម រង្ស៊ី នឹងរៀបចំប្រារព្ធពិធីបុណ្យខួបលើកទី១៤ នៅមុខអតីតមន្ទីររដ្ឋសភា ដើម្បីគោរពវិញ្ញាណក្ខន្ធវីរបាតុករ ដែលបានបាត់បង់ជីវិត ដោយអំពើភេរវកម្មវាយប្រហារដោយគ្រាប់បែកដៃចំនួន៤គ្រាប់ ទៅលើក្រុមបាតុករអហិង្សា និងសន្តិវិធី ដែលឈរទាមទារឲ្យមានការកែទម្រង់ប្រព័ន្ធតុលាការនៅមុខមន្ទីររដ្ឋសភា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ។ ភេរវកម្មដ៏សាហាវព្រៃផ្សៃនេះ បានបណ្តាលឲ្យបាតុករ និងប្រជារាស្ត្រស្លូតត្រង់ប្រមាណ២០នាក់ស្លាប់បាត់បង់ជីវិត និងជាង១០០នាក់រងរបួស ។

ព្រឹត្តិការណ៍ដ៏សាហាវព្រៃផ្សៃ និងខ្លោចផ្សានេះ គណបក្ស សម រង្ស៊ី មិនអាចបំភ្លេចបានឡើយ ហើយគណបក្សបានរៀបចំពិធីបុណ្យខួបរំលឹកវិញ្ញាណក្ខន្ធជារៀងរាល់ឆ្នាំ ដើម្បីសំដែងនូវការគោរព ការដឹងគុណ និងការចងចាំជានិច្ចចំពោះគំរូវីរភាពដ៏ឧត្តុង្គឧត្តមរបស់វីរបាតុករ ដែលបានធ្វើពលិកម្មដើម្បីបុព្វហេតុសេរីភាព យុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា ។

សេចក្តីដូចបានជំរាបជូនខាងលើ គណបក្ស សម រង្ស៊ី សូមគោរពអញ្ជើញជនរួមជាតិ និងសប្បុរសជនដែលស្រឡាញ់យុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យ មេត្តាចូលរួមចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួនក្នុងពិធីនេះ ដើម្បីឧទ្ទិសកុសលផលបុណ្យ ជូនដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ដើម្បីបុព្វហេតុសេរីភាព យុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យ នៅប្រទេសកម្ពុជា ។

គណបក្ស សម រង្ស៊ី សូមថ្លែងអំណរគុណទុកជាមុន ចំពោះសមានចិត្តសប្បុរសធម៌របស់បងប្អូនជនរួមជាតិដែលបានជួយជ្រោមជ្រែងទាំងផ្នែកស្មារតី សម្ភារៈ និងថវិកា ដល់ការប្រារព្ធពិធីបុណ្យនេះ ៕

*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១*

**អគ្គលេខាធិការគណបក្ស**

**កែ សុវណ្ណរតន៍**

**អាសយដ្ឋានទំនាក់ទំនង :**

*- ទីស្នាក់ការកណ្តាលគណបក្ស សម រង្ស៊ី ផ្ទះលេខ៧១ វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន*

*- ទូរស័ព្ទ : ០៩២ ៤៣៤ ០១០ , ០១២ ៧៥៣ ៨៧៧*

*- អ៊ីម៉ែល : srphqpp@gmail.com , srpcabinet@gmail.com*